# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

**ប្រចាំខែកក្កដា ឆ្នាំ២០១៦ / July 2016**

## ខ្លឹមសារសង្ខេប

**១.** ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែឧសភា ឆ្នាំ២០១៦ បានកើនឡើង ០,៤% ធៀបនឹងខែកន្លងទៅ និងបានកើនឡើង ៣,១% ធៀបនឹង១២ខែមុន។ សន្ទស្សន៍ថ្លៃទំនិញដែលបានកើនឡើងគួរកត់សម្គាល់ធៀបនឹងខែមុនគឺ (១)សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ទនៈដទៃទៀតបានកើនឡើង ១,២% ក្នុងនោះថ្លៃឧស្ម័នកើនឡើង ៩,៨% (២)សន្ទស្សន៍ថ្លៃដឹកជញ្ជូនបានកើនឡើង ១,៧% ក្នុងនោះថ្លៃប្រេងឥន្ទនៈនិងខ្លាញ់កើនឡើង ៤,៨% ថ្លៃសាំងធម្មតាកើនឡើង ៥,០% និងថ្លៃប្រេងម៉ាស៊ូតកើនឡើង ៣,១% ដោយសារថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិមានការកើនឡើង។ ចំណែកឯសន្ទស្សន៍ថ្លៃនៃក្រុមទំនិញផ្សេងទៀតស្ថិតបាននៅនឹង ឬបានថយចុះតិចតួចដោយសារមានការថយចុះតម្រូវការប្រើប្រាស់ក្រោយរដូវកាលបុណ្យចូលឆ្នាំខ្មែរ។

**២.** គិតត្រឹមខែឧសភា ឆ្នាំ២០១៦ រូបិយវត្ថុទូទៅM2មាន ៥៣.៣១៤ពាន់លានរៀល បានកើនឡើង ១៨,៩%ធៀបនឹង១២ខែមុន ក្នុងនោះប្រាក់រៀលមានសន្ទុះកើនឡើងខ្លាំង ក៏ប៉ុន្តែរូបិយប័ណ្ណបរទេសនៅតែមានចំណែកធំ ដោយបញ្ញើជារូបិយប័ណ្ណបរទេសមាន ៨៤,៣%។

តាមការសង្កេត តម្រូវការសាច់ប្រាក់ក្នុងសេដ្ឋកិច្ចនៅបន្តកើនឡើង។ ជាក់ស្តែង ឥណទានផ្តល់ដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុមាន ៤៤.៩៦៣ពាន់លានរៀល បានកើនឡើង ២៨%ធៀបនឹង១២ខែមុន ក្នុងនោះមានឥណទានផ្តល់ដល់វិស័យសំណង់មាន ៩,៤% សេវាកម្ម ៦៨,១% កសិកម្ម ១៣,០% និងឧស្សាហកម្ម ៩,៥%។ រីឯឥណទានផ្តល់ដល់វិស័យហិរញ្ញវត្ថុមាន ១.៣៧៥ពាន់លានរៀល កើនឡើង ៦៧,៣%ធៀបនឹង១២ខែមុន បើទោះបីជាបានថយចុះបន្តិចបន្តួចធៀបនឹងខែមេសាកន្លងទៅ។

ការកើនឡើងតម្រូវការសាច់ប្រាក់ បានទាញអត្រាការប្រាក់នៅកម្ពុជាកើនឡើង ទោះបីជាវិស័យធនាគារនៅកម្ពុជាបាននឹងកំពុងលូតលាស់យ៉ាងឆាប់រហ័សក៏ដោយ។ ជាក់ស្តែង អត្រាការប្រាក់នៅកម្ពុជាមានកម្រិតខ្ពស់ជាងបណ្តាប្រទេសក្នុងតំបន់ ដែលនេះមួយផ្នែកបង្ហាញថាកម្ពុជាមានសក្តានុពលសេដ្ឋកិច្ចលូតលាស់ខ្លាំង និងកំពុងត្រូវការទុន ប៉ុន្តែព្រមគ្នានេះក៏តម្រូវឲ្យបង្កើនការគ្រប់គ្រងលំហូរទុនប្រកបដោយការប្រុងប្រយ័ត្ន និងធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃប្រតិបត្តិការ។

**៣. ការនាំចូល-នាំចេញ÷** ការនាំចូលក្នុងរយៈពេល៦ខែ ឆ្នាំ២០១៦នេះ មានការកើនឡើងបើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៥ បើទោះបើមានការធ្លាក់ចុះបន្តិចនៅក្នុងខែមិថុនានេះ ដោយសារការនាំចូលសម្ភារៈបរិក្ខារ

សំណង់បានថយចុះ ២៧% ផលិតផលវាយនភ័ណ្ឌថយចុះ ៧% និងគ្រឿងយន្តថយចុះ ៥% ប៉ុន្តែប្រេងឥន្ធនៈបានកើនឡើង ១៦%។ ចំណែកឯការនាំចេញជាទឹកប្រាក់បានបន្តកើនឡើងរាល់ខែនៅឆមាសទី១ ជាក់ស្តែងក្នុងខែមិថុនានេះមាន ៩៤៦លានដុល្លារ បានកើនឡើង២៧%ធៀបនឹងខែមុន ដោយសារការនាំចេញផលិតផលវាយនភ័ណ្ឌនិងស្បែកជើងបានហក់ឡើងខ្លាំង ដែលគិតជាទឹកប្រាក់មាន ៦៨៦លានដុល្លារ។

**៤. ការអនុវត្តចំណូល៖** នៅខែមិថុនាឆ្នាំ២០១៦ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលក្នុងប្រទេសសរុបបានចំនួន ១.១៧២,៦២ប៊ីលានរៀល គឺបានកើនឡើង ២២,៤%ធៀបនឹងខែមិថុនា ឆ្នាំ២០១៥ ប៉ុន្តែបានថយចុះធៀបនឹងខែមុន ដោយសារការបន្តថយចុះនៃចំណូលពន្ធលើប្រាក់ចំណេញ ដែលបណ្តាលមកពីការចប់អាណត្តិនៃការប្រកាសពន្ធរបស់សហគ្រាសឯកជន ការថយចុះនៃផលពីសកម្មភាពទេសចរណ៍ ចំណូលពីប្រៃសណីយ៍និងទូរគមនាគមន៍ និងចំណូលមិនមែនពន្ធផ្សេងទៀត ជាពិសេសចំណូលកាតព្វកិច្ចកាស៊ីណូ។ ទោះយ៉ាងណាក្តី ចំណូលក្នុងស្រុកក្នុង៦ខែឆ្នាំ២០១៦នេះ នៅបន្តមានលទ្ធផលល្អដោយអនុវត្តបានលើសផែនការថវិកាប្រចាំឆ្នាំ៤,៥៣%។

**ការអនុវត្តចំណាយ៖** នៅខែមិថុនា ឆ្នាំ២០១៦ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណាយថវិកាសរុបបានចំនួន ១.៣៤៩,២៦ ប៊ីលានរៀល គឺបានកើនឡើង ៣៨,១% ធៀបនឹងខែមុន និងបានកើនឡើង ២២,៨% ធៀបនឹងខែមិថុនា ឆ្នាំ២០១៥។ ការកើនឡើងនេះ គឺបណ្តាលមកពីការកើនឡើងនៃចំណាយបៀវត្ស ចំណាយមិនមែនបៀវត្ស ជាពិសេស ចំណាយលើអត្ថប្រយោជន៍សង្គម ដែលបានបង្ហាញពីការគិតគូររបស់រាជរដ្ឋាភិបាលក្នុងការជួយដល់ប្រជាពលរដ្ឋ។ មួយវិញទៀត កំណើននេះក៏បណ្តាលមកពីការកើនឡើងនៃចំណាយវិនិយោគក្នុងខែមិថុនានេះ។ ជាលទ្ធផល តុល្យភាពថវិកាចរន្តនៅខែមិថុនា ឆ្នាំ២០១៦ មានអតិរេកសាច់ប្រាក់ចំនួន ៣៨៥,៨៤ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានឱនភាពសាច់ប្រាក់ចំនួន ១០៥,៦០ប៊ីលានរៀល។

**៥.** តាមការសង្កេតក្នុងរយៈពេល៦ខែ ឆ្នាំ២០១៦នេះ សំណើវិនិយោគដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាគិតជាទឹកប្រាក់សរុបមាន ១.៧៨២លានដុល្លារ បានថយចុះ ៤៣%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៥ ក្នុងនោះថយចុះខ្លាំងលើវិស័យកសិកម្ម និងវិស័យសេវាកម្ម ដោយសារកាលក្នុងខែមីនាឆ្នាំ២០១៥មានគម្រោងវិនិយោគធំៗមួយចំនួន ក្នុងទឹកប្រាក់ ២.៦៨៦លានដុល្លារ រួមមានការបង្កើតសហគ្រាសផលិតស្ករអំពៅ២គម្រោងក្នុងទឹកប្រាក់ ២១០លានដុល្លារ សហគ្រាសកែច្នៃដំឡូងមី១គម្រោងក្នុងទឹកប្រាក់ ៣៥លានដុល្លារ គម្រោងអភិវឌ្ឍន៍បឹងកក់ក្នុងទឹកប្រាក់ ២.១៧១លានដុល្លារ និងគម្រោងស្ថាបនាបណ្តាញទូរគមនាគមន៍អន្តរជាតិក្នុងទឹកប្រាក់ ២៧០លានដុល្លារ។ ជារួម ទោះមានការធ្លាក់ចុះទុនវិនិយោគសរុបក្នុងអំឡុងពេល៦ខែនេះក្តី ក៏នៅតែមានកំណើនខ្ពស់នូវការវិនិយោគលើវិស័យឧស្សាហកម្ម(កើនឡើងជិត៣ដង) និងវិស័យទេសចរណ៍(កើនឡើងជិត១០ដង)។

**៦.** ក្នុងរយៈពេល៥ខែឆ្នាំ២០១៦នេះ ចំនួនទេសចរអន្តរជាតិសរុបមានការកើនឡើង ២,៤% ធៀបនឹងរយៈពេលដូចក្នុងឆ្នាំមុន ក្នុងនោះ ចំនួនទេសចរអ៊ឺរ៉ុបនិងអាមេរិកកើនឡើង ៧,៦% និង១១%រៀងគ្នា និងទេសចរ

អាស៊ីខាងត្បូងកើនឡើង ២៨,១%។ ប៉ុន្តែក្នុងខែឧសភា ឆ្នាំ២០១៦នេះ ចំនួនទេសចរអន្តរជាតិសរុបមានការថយចុះ បើធៀបនឹងខែមុន និងជាអំឡុងពេលដែលចំនួនភ្ញៀវអន្តរជាតិមានកម្រិតទាប ដោយសារលក្ខណៈអាកាសធាតុ ហើយចំនួនភ្ញៀវទេសចរនឹងមានកំណើនឡើងតិចតួចមកវិញក្នុងខែកក្កដានិងសីហាខាងមុខ។

**៧.** បើសង្កេតមើលរយៈពេល ៦ខែ ឆ្នាំ២០១៦ សំណើសាងសង់មានចំនួន១.១៨៣គម្រោង គិតជាផ្ទៃក្រឡាសាងសង់មាន ១០.៥១២ពាន់ម៉ែត្រការ៉េ មានការកើនឡើងគួរឲ្យកត់សម្គាល់ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៥ ជាពិសេសសំណង់ប្រភេទអាគារពាណិជ្ជកម្ម (កើនឡើងប្រហែល ១០ដង) សំណង់លំនៅដ្ឋាន សំណង់ប្រភេទឧស្សាហកម្ម និងសំណង់ប្រភេទទេសចរណ៍។ ប៉ុន្តែក្នុងខែមិថុនា ឆ្នាំ២០១៦ សំណើសាងសង់សរុបមានការថយចុះធៀបនឹងខែមុន ដោយសារការធ្លាក់ចុះផ្ទៃក្រឡាសាងសង់ជាប្រភេទលំនៅដ្ឋាន ពាណិជ្ជកម្ម និងទេសចរណ៍។

**៨. ថ្លៃប្រេងឆៅ** ក្នុងខែមិថុនា ឆ្នាំ២០១៦នេះ ថ្លៃប្រេងឆៅមានការប្រែប្រួលតិចតួច ប៉ុន្តែបើគិតជាថ្លៃមធ្យមប្រចាំខែធៀបនឹងខែកន្លងទៅ ថ្លៃប្រេងឆៅក្នុងកិច្ចសន្យាលក់១ខែខាងមុខបានកើនឡើង ៣,៨%(កើនពី ៤៥,៩៤ដុល្លារ/ធុងទៅ ៤៧,៦៩ដុល្លារ/ធុង) ក្នុងនោះថ្លៃមធ្យមប្រចាំខែនៃប្រេងBrentបានកើនឡើង ២,៩% និងប្រេងWTIបានកើនឡើង ៤.៣%។ កំណើននេះគឺបណ្តាលមកពីកត្តាតម្លៃប្រាក់ដុល្លារមានការថយចុះ ការថយចុះនៃប្រេងស្តុករបស់សហរដ្ឋអាមេរិក គម្រោងបាតុកម្មកម្មករប្រេងនំរវេស និងកត្តាបរិយាកាសវិបត្តិឧស្សាហកម្មប្រេងនៅវេណេហ្ស៊ុយអេឡាផងដែរ។

**ថ្លៃអង្ករ** គិតត្រឹមខែមិថុនា ឆ្នាំ២០១៦ (១)*អង្ករកម្ពុជា* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៤៦០ដុល្លារ/តោន បានកើនឡើង ២,២%ធៀបនឹងខែមុន និងកើនឡើង ៥,៧%ធៀបនឹង១២ខែមុន។ កំណើននេះមួយផ្នែកគឺដោយសារតម្រូវមានការកើនឡើង ស្របពេលការប្រមូលផលរបស់ប្រទេសផលិតអង្ករមួយចំនួនបានថយចុះ ដោយសារគ្រោះរាំងស្ងួត។ (២)*អង្ករថៃ* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៤៤១ដុល្លារ/តោន បានកើនឡើង ១,៨%ធៀបនឹងខែមុន និងកើនឡើង១៧,៣%ធៀបនឹង១២ខែមុន ដោយសារតម្រូវការទីផ្សារទាំងក្នុងស្រុកនិងក្រៅស្រុកកំពុងកើនឡើង ដូចជាការដោះដូររវាងរដ្ឋនិងរដ្ឋ ដូចជាការបញ្ជាទិញអង្កររបស់ប្រទេសចិនចំនួន ១លានតោនសម្រាប់ខែសីហាខាងមុខនេះ ហើយប្រទេសនាំចូលអង្ករមួយចំនួនទៀតដូចជា ហ្វីលីពីននិងឥណ្ឌូនេស៊ីកំពុងធ្វើលទ្ធកម្មអង្ករបន្ថែម ព្រមទាំងការថយចុះទិន្នផលស្រូវនៃប្រទេសឥណ្ឌានិងវៀតណាមដោយភាពរាំងស្ងួត។ (៣)*អង្ករវៀតណាម* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៣៧២,៤៦ដុល្លារ/តោន បានថយចុះ ១,៣%ធៀបនឹងខែមុន ប៉ុន្តែបានកើនឡើង ៦,៧% ធៀបនឹង១២ខែមុន។ ការធ្លាក់ចុះនេះ បណ្តាលមកពីឥទ្ធិពលនៃការប្រកួតប្រជែងជាមួយប្រទេសថៃ។

**ថ្លៃកៅស៊ូ** ក្នុងខែមិថុនា ឆ្នាំ២០១៦ ថ្លៃកៅស៊ូមាននិន្នាការថយចុះក្នុងកន្លះខែដំបូង និងកើនឡើងមកវិញក្នុងកន្លះខែបន្ទាប់។ ជារួម នៅខែមិថុនា កៅស៊ូឆៅស្តង់ដារ TSR20ថ្លៃ ១.២៧៨,៥ដុល្លារ/តោន ថយចុះ ៦,៥% ធៀបនឹងខែមុន និងថយចុះ ១៩,៦%ធៀបនឹងខែមិថុនា ឆ្នាំ២០១៥។ កៅស៊ូ SGP/MYSថ្លៃ ១.៥៨០,៦ដុល្លារ/តោន

បានថយចុះ ៥,៦%ធៀបនឹងខែមុន និងថយចុះ ១៣,៦%ធៀបនឹង១២ខែមុន។ ការធ្លាក់ថ្លៃកៅស៊ូធៀបនឹងខែកន្លងទៅ គឺដោយសាររយៈកាលថ្មីៗនេះជាពេលប្រមូលផលកៅស៊ូក្នុងបណ្តាប្រទេសផលិតកៅស៊ូក្នុងតំបន់អាស៊ាន និងខេត្តហៃណានប្រទេសចិន ដែលនាំឲ្យមានកំណើនការផ្គត់ផ្គង់។

*********

**រៀបចំដោយ**

**នាយកដ្ឋានស្ថិតិ**

**អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*Statistics Department*

*General Department of Economic and Public Finance Policy*

*Ministry of Economy and Finance*